# តើអ្វីទៅ ធម៌

*តាម ព្រះពុទ្ធសាសនា ពាក្យថា ធម៌ នេះ មានន័យទូលំទូលាយណាស់ ។ ធម៌ គឺ ច្បាប់ធម្មជាតិ ។ ចំពោះអ្នកកាន់ព្រះពុទ្ធសាសនា ធម៌ គឺ ពាក្យប្រៀនប្រដៅរបស់ព្រះ ពុទ្ធ ។ យើងរស់នៅសព្វថ្ងៃនេះ គឺនៅក្រោមច្បាប់ ធម្មជាតិយើងគេចពីច្បាប់ធម្មជាតិមិនបានទេ ។ ច្បាប់ធម្មជាតិមួយ ដែលយើងគេចមិនរួច គឺ « តែមានការកើត ត្រូវតែមានការស្លាប់ » ។ ដើម្បីយើងបានសុខ ទាល់តែយើង រស់នៅឲ្យស្របនឹង ច្បាប់ ធម្មជាតិ ។ ដូចជាច្បាប់ មួយ ដែល គេច្រើនតែភ្លេច គឺ ៖*

*« សត្វលោកទាំងអស់ (មិនថា មនុស្ស ឬ សត្វតិរច្ឆាន)សុទ្ធតែ ចង់បានសេចក្ដីសុខទាំងអស់គ្នា ហើយក៏មិនចង់ជួបនឹង ការទុក្ខលំបាកដែរ » ។ បើដូច្នេះ យើងគប្បីកុំធ្វើបាប អ្នកដទៃ ដោយប្រការណាមួយឡើយ ។*

## ៧

## ធម៌

*យើងច្រើនឮ គេនិយាយពាក្យ ធម៌ កាលណាគេនិយាយពីសាសនា ។ ដូចជាធម៌នៅក្នុង គ្រីស្តសាសនា នៅក្នុង សាសនាអ៊ីស្លាម នៅក្នុង ព្រហ្មញ្ញសាសនា នៅក្នុង ពុទ្ធសាសនា ជាដើម ។ នៅពេលនេះ ខ្ញុំសូមលើកតែ ធម៌ បីពួក មកអធិប្បាយ គឺ ១-ធម៌ពិត* (la Vérité) *២-ធម៌នៃសាសនាដទៃពីពុទ្ធសាសនា ៣-ធម៌នៅក្នុងពុទ្ធសាសនា ។*

<u>*ធម៌ពិត* (la Vérité)</u>

*ធម៌ពិត គឺធម៌ដែលត្រូវតែមាន ទោះបីអ្នកនោះ ជឿ ឬ មិនជឿ សាសនាណាមួយ*

ក៏ដោយ។ ឧបមា ដូចយើង ឈរហាលភ្លៀង ដោយអត់មានឆ័ត្របាំងក្បាល នោះមុខជាទទឹកភ្លៀងហើយ ទោះបី យើងកាន់ ឬ មិនកាន់សាសនាក៏ដោយ ។ មកដល់ត្រង់នេះ សូមជំរាបពីខ្លួនខ្ញុំ ដែលជាអ្នកកាន់ពុទ្ធសាសនា ។ កាលខ្ញុំនៅក្មេង ចាស់ៗ អ្នកកាន់សីល ក្នុងព្រះពុទ្ធសាសនា គាត់ប្រាប់ខ្ញុំថា « លោកយាយនេះ គាត់មានរូបរាងស្អាត មកពីជាតិមុនគាត់កាន់សីល ហើយជាតិនេះគាត់ក្រ មកពីជាតិមុនគាត់មិនសូវបានធ្វើបុណ្យ ដាក់ទាន » ។ គាត់មានប្រសាសន៍ បែបនេះ ខ្ញុំអត់មានភ្ញាក់ផ្អើលអ្វីទេ ពីព្រោះនៅស្រុកខ្មែរមនុស្សកាន់ពុទ្ធសាសនា ស្ទើរតែទាំងអស់គ្នាទៅ ហើយ ។ តែដល់ខ្ញុំមករស់នៅស្រុកបារាំង ដែល អ្នកកាន់ពុទ្ធសាសនាស្ទើរតែគ្មាន ហើយក៏មានមនុស្សរូបរាងស្អាតៗច្រើនដែរនោះ ធ្វើឲ្យខ្ញុំសួរថា ហេតុអ្វី ក៏អ្នកដែលមិនកាន់ព្រះពុទ្ធសាសនា ក៏គេមានរូបល្អដែរ ។ ចម្លើយរបស់ខ្ញុំគឺថា គេមិនកាន់ព្រះពុទ្ធសាសនាមែនតែអំពើដែលគេធ្វើ ត្រូវនឹងសីល៥ ក្នុងព្រះពុទ្ធសាសនា ដូចជា មិននិយាយពាក្យអាក្រក់ ជេរប្រទេចគេ ឬ ក៏និយាយពាក្យពេយពាយឥតប្រយោជន៍ជាដើម ។ នេះបញ្ជាក់ថា <u>ធម៌ពិត នៅតែជាធម៌ពិត ដដែល</u> ទោះបីយើងចង់ឬ មិនចង់ក៏ដោយ ។ យើងត្រូវហ៊ាន មើលការពិត សាសនា មិនអាចជួយយើងបានទេ បើសម្លាប់គេ មុខជាបាបហើយ ! ព្រោះហេតុអ្វី ព្រោះថា តើយើងសុខចិត្តឲ្យគេមកសម្លាប់យើងទេ ? យើងមិនសុខចិត្ត ពីព្រោះយើងខ្លាចសេចក្តីស្លាប់ ។ បើយើងខ្លាចស្លាប់ គេក៏ខ្លាចស្លាប់ដែរ ។ ធម៌ពិត (la Vérité) មិនមែនជាធម៌របស់សាសនាណាមួយទេ ។ សាសនាកើតក្រោយ ធម៌ពិត ទេ ។ ចូរកុំទាស់គ្នាពីព្រោះតែការប្រកាន់សាសនារៀងៗខ្លួន។

<u>ធម៌ក្រៅពុទ្ធសាសនា</u>

គឺធម៌ ដែលមិនមែនជាធម៌ព្រះពុទ្ធ ដូចជាថា ៖ មនុស្សយើងម្នាក់ៗ មាន អាត្ម័ន មាន ព្រលឹង អមតៈ(មិនស្លាប់) បន្តពីជាតិមួយទៅជាតិមួយជានិច្ច ជាដើម ។

*ធម៌នៅក្នុងពុទ្ធសាសនា*

*ខ្ញុំ មិននិយាយថាធម៌* ***របស់*** *ពុទ្ធសាសនាទេ   ពីព្រោះធម៌ទាំងអស់មានរួចមកហើយ ព្រះពុទ្ធ* ***មិនបានបង្កើត*** *ធម៌ដែលព្រះអង្គបានសម្ដែងនោះទេ  យើងសួរថាបើព្រះអង្គមិនបង្កើត ហើយដោយមុនព្រះអង្គត្រាស់ដឹង ធម៌ខ្លះមិនដែលមានផង ដូចជា អរិយសច្ច ជាដើម តើអ្នកណាបង្កើតធម៌នោះ ?  មុននឹងឆ្លើយខ្ញុំសូមធ្វើការវែកញែក រវាងពាក្យ « បង្កើត »  និងពាក្យ « រកឃើញ » ។ បង្កើត  បានន័យថា បង្កើតអ្វីៗ  ដែលមិនទាន់មាន ហើយធ្វើឲ្យមានឡើង ដូចជាម្ដាយបង្កើតកូន។  ចំពោះពាក្យ  « រកឃើញ » គឺ រកឃើញ នូវរបស់អ្វីដែលបាត់បង់ ពោលគឺរបស់នោះមាន តែមិនដឹងនូវឯណា ដូចជា រកឃើញ នូវកំណប់  ឬ ដូចជាអ្នកវិទ្យាសាស្ត្រ រកឃើញ រូបមន្ត នៃច្បាប់ធម្មជាតិ  ឬ  ព្រះពុទ្ធរកឃើញធម៌នាំទៅនិព្វាន ជាដើម ។ បានន័យថា* **និព្វាន** *មាន  តែមុនព្រះពុទ្ធត្រាស់ដឹង នៅលើលោកយើងសព្វថ្ងៃនេះ មិនទាន់មានអ្នកណាមួយរកឃើញនៅឡើយ ។ តែព្រះពុទ្ធទាំងឡាយ ដែលបានត្រាស់ដឹង សុទ្ធតែបានរកឃើញនូវធម៌នាំទៅនិព្វាននេះជានិច្ច ។ យើងសួរថាតើសំអាងលើអ្វីថា និព្វានមាន ?  ដោយ ទាំងលោកអ្នកខ្លះ  ទាំងខ្ញុំ សុទ្ធតែមិនដែលឃើញនិព្វានដូចតែគ្នា  នេះស្រេចតែទៅលើ ជំនឿ ឬ ការទុកចិត្តលើការត្រាស់ដឹងនៃព្រះពុទ្ធ  រៀងៗខ្លួន ។  ចំពោះអ្នក ទុកចិត្តលើការត្រាស់ដឹងនៃព្រះពុទ្ធ  គឺ គេសំអាងថា មុនព្រះសម្មាសម្ពុទ្ធគោតម ក៏មានព្រះពុទ្ធច្រើនព្រះអង្គបានសម្រេចនិព្វានរួចទៅហើយ  លុះដល់សម័យព្រះពុទ្ធគោតម  ព្រះអង្គ ព្រមទាំងសាវកជាច្រើន ក៏បានសម្រេចនិព្វានដែរ ។  ដូច្នេះ និព្វាន [1]មាន ។*

---

[1] *នេះជាយោបល់ខ្ញុំផ្ទាល់ទេ ចំពោះ**និព្វាន** ៖ ចំពោះនិព្វាន ដោយមិនមានសភាពដូចអ្វីៗដែលមាននៅក្នុងលោកយើងសព្វថ្ងៃនេះទេ តើមានពាក្យឯណា មកពន្យល់ មកឲ្យនិយមន័យនិព្វានបាន ។ ឧបមាដូចរថយន្តយើងជិះសព្វថ្ងៃនេះ  យើងអាចរកពាក្យមកពិព៌ណនាអំពីរថយន្តបាន តែបើសម័យ*

យើងសួរថា ធម៌កើតនៅពេលណា អ្នកណាបង្កើតធម៌នោះ? នេះចូលមកដល់សំណួរ សត្វលោក កើតនៅពេលណា អ្នកណាជាអ្នកបង្កើត សំណួរទាំងនេះ មិនងាយឆ្លើយ ឲ្យត្រូវចិត្តគ្រប់ៗគ្នាបានទេ យើងមើលរហូតមកដល់សព្វថ្ងៃនេះ ចំពោះសំណួរ ថាតើ « **ព្រះ មាន ឬ មិនមាន** » ( Est-ce Dieu existe ?) ក៏គ្មានចម្លើយត្រូវគ្នាដែរ ។ ម្យ៉ាងទៀត ទោះបីជាមានចម្លើយក៏ដោយ ក៏ចម្លើយទាំងនោះពុំអាចដោះស្រាយនូវបញ្ហា ទុក្ខនៃ មនុស្សលោកបានដែរ ។ ដូច្នេះនាំតែខាតពេល នាំតែបង្កើតសង្គ្រាមសាសនាពីព្រោះ តែសំណួរគ្មានចម្លើយនោះ ។ ដោយយើងរស់នៅក្នុងធម្មជាតិ ដូច្នេះយើង ត្រូវស្គាល់ច្បាប់ធម្មជាតិដើម្បីបានសុខ ហេតុនេះហើយ បានជាធម៌ដែលព្រះពុទ្ធ រកឃើញ ហៅថាច្បាប់ធម្មជាតិ ។ ធម៌របស់ព្រះអង្គ យកច្បាប់ធម្មជាតិជាគោល ។ ពាក្យថា **ធម៌** ក្នុងព្រះពុទ្ធសាសនាមានន័យច្រើនណាស់ គឺសភាវៈ ទ្រទ្រង់សត្វលោក ដូចជា បុណ្យ បាប កុសល អកុសល និព្វាន ហេតុ ធម្មតា ប្រក្រតី ធម្មជាតិ ប្រាជ្ញាញាណ កិរិយាមារយាទ ជាដើមៗ បន្ទាប់មក មានពាក្យ សង្ខារធម៌ គឺ ធម៌ ដែលកើតឡើង ដោយគ្រឿងប្រកប តាក់តែង ប្រមូលផ្សំ ដែលហៅថាសង្ខារ ។

---

ព្រះពុទ្ធ ដែលមិនទាន់មានរថយន្តផង តើឲ្យអ្នកសម័យនោះពិព៌ណនាអំពីរថយន្ត ដូចម្តេចកើត។ ហេតុនេះហើយបានជាមកដល់សព្វថ្ងៃនេះ ក្នុងគម្ពីរ បើថ្លែងអំពីនិព្វាន គេច្រើនតែនិយាយនូវអ្វីដែល <u>**មិនមែនជានិព្វានទៅវិញ**</u> ។ ដូចជានិព្វាន មិនមែនជាសង្ខារធម្ម មិនមានកើត មិនមានស្លាប់ ជាដើម ។ ហើយអ្នកខ្លះ ដល់ថាមិនមានកើត ក៏បកស្រាយថានិព្វាន គឺ សូន្យ ហើយក៏មិនចង់ទៅនិព្វានទេ ពីព្រោះមិនចង់សូន្យ ។ នេះហើយការបកស្រាយ នូវអ្វីៗ ដែលយើងមិនទាន់ស្គាល់ មិនទាន់ឃើញ មិនទាន់ទៅដល់ ។ ចំពោះខ្ញុំវិញ ជាអ្នកបដិបត្តិធម៌ព្រះ ដោយខ្ញុំយល់ដោយខ្លួនខ្ញុំថា មគ្គប្រកបដោយអង្គ៨ នឹងផ្តល់ឲ្យខ្ញុំនូវសេចក្តីសុខដោយ <u>ពិតប្រាកដ</u> នោះខ្ញុំគ្រប់គ្រាន់ហើយ ខ្ញុំមិនចំណាយពេលសួរដេញដោល រកចម្លើយដែលយើងមិនដឹងដូចតែគ្នានោះទេ ។ ទោះបីព្រះសង្ឃក៏លោកឆ្លើយតែតាមគម្ពីរដែរ ប្រសិន បើសព្វថ្ងៃនេះ មានព្រះអរហន្ត ដូចកាលសម័យព្រះពុទ្ធ នោះលោកអាចពន្យល់យើងបានខ្លះ ។

ឧបមាដូច សម្ល៉កកូរ ជា សង្ខារធម៌ ពីព្រោះកើតឡើង ដោយផ្សំគ្រឿងជាច្រើន ដូចជា អង្ករលីញ ល្ពុងខ្ចី សាច់ត្រី ទឹកត្រី ទឹក ជាដើម ។ ហើយ ទឹកត្រី ក៏ជាសង្ខារធម៌ដែរ ពីព្រោះ ផ្សំដោយស្មោជាមួយគ្នា កូនត្រី អំបិល ទឹក ជាដើម ។ ហើយទឹក ក៏ជាសង្ខារធម៌ទៀត ពីព្រោះតាមអ្នកវិទ្យាសាស្ត្រខាងគីមី ថាទឹកផ្សំដោយ ខ្យល់ អុកស៊ីសែន និង អ៊ីដ្រូសែន ។ ក្នុងឧទាហរណ៍ទឹកត្រីនេះ យើងឃើញថា សង្ខារធម៌ នីមួយៗសុទ្ធតែផ្សំដោយសង្ខារធម៌ឯទៀត ដែលផ្សំដោយសង្ខារធម៌ ឯទៀតៗ ចេះតែតៗទៅ តូចៗទៅ ល្អិតៗទៅ ដូចយើងធ្លាប់ឮហើយថា កិលេស ក៏មានកិលេសតូចសុខុម ហៅថា អនុស្ស័យកិលេសដែរ ។ ដូច្នេះសង្ខារធម៌ ត្រូវតែប្រែប្រួល កាលណាគ្រឿងផ្សំណាមួយប្រែប្រួល ដូចជាសម្ល៉កកូរ ត្រូវប្តូរគុណភាព ដូចជាផ្អូមជាដើម កាលណាគ្រឿងផ្សំណាមួយវាប្តូរគុណភាពៗ នេះជាភាព ចំណុះគ្នា ប្រទាក់ប្រទងគ្នាទៅវិញទៅមកនៃសង្ខារធម៌ ។ ដូចជា វិបត្តិសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក ធ្វើឲ្យសេដ្ឋកិច្ចទ្វីបអឺរុប ចុះថយដែរ ។ ដោយ<u>តាមច្បាប់ធម្មជាតិ</u> អ្វីៗក្នុងលោកនេះ សុទ្ធតែមិនទៀង ដូច្នេះ សង្ខារធម៌ ក៏មិនទៀងដែរ ។ <u>មានច្បាប់ធម្មជាតិមួយទៀត</u> គឺ **កើត រលត់**

កាលណាមានការកើត ត្រូវតែមានការរលត់ ។ យើងថាច្បាប់ធម្មជាតិ ពីព្រោះតាមការសង្កេតមកពុំដែលមានទេ មនុស្សមិនស្លាប់ គឺ **អមតៈ**។ អ្នកអាយុវែង បានយ៉ាងច្រើនលើសពី ១០០ឆ្នាំ ហើយហួសពី ១០០ឆ្នាំទៅ បើនៅរស់ក៏មិនសប្បាយណាស់ណាដែរ ពីព្រោះរាងកាយទាំងមូល កាន់តែចាស់ទ្រុឌទ្រោម ភ្នែកក៏ស្រវាំង ត្រចៀកក៏ធ្ងន់ ។ បើនិយាយអំពី សង្ខារធម៌វិញ ធម៌ទាំងឡាយតែងតែ កើត តាំងនៅ រលត់ ។ អ្វីៗទាំងពួងក្នុងលោកសុទ្ធជា សង្ខារធម៌ គឺ ធម៌ដែលកើតឡើង ដោយ គ្រឿងប្រកបតាក់តែងដោយប្រមូលផ្សំ ។ មនុស្សយើងក៏ជាសង្ខារធម៌ ភ្លើងទៀនដែលកំពុងតែឆេះក៏ជាសង្ខារធម៌ ។ ភ្លើងទៀន ដែលឆេះរលត់ ឆេះរលត់ តៗគ្នា មើលទៅហាក់ដូចជាភ្លើងតែមួយ

ដែលឆេះរហូតហើយរលត់ទាល់តែអស់ទៀន ឬ ក៏យើងពន្លត់ ។ តាមពិត ភ្លើងទៀន ឆេះរលត់ ឆេះរលត់ ជាបន្តគ្នា ជាប់រហូត ។ គ្រាន់តែ មុននឹងរលត់ ភ្លើងនោះជាហេតុ ឲ្យមានភ្លើងឆេះបន្ត ដូចជា មនុស្សយើង នៅពេលមុនស្លាប់ ចុតិចិត្ត (ចិត្តនៅពេល ដង្ហើមចុងក្រោយមុនដាច់ខ្យល់) នៅភពបច្ចុប្បន្ន រលត់ បណ្តាលឲ្យ បដិសន្ធិចិត្ត នៅភពថ្មី កើតបន្តភ្លាម រួចហើយទើបចិត្តនោះចូលភវង្គ គឺ ធ្វើកិច្ចរក្សាភព ជាបន្តក្នុង កំណើតថ្មី ។ ដូច្នេះ យើងឃើញថា ស្លាប់ហើយកើត (បដិសន្ធិ)ភ្លាមៗ តែត្រូវទៅកើត នៅឋានណា ឬ កន្លែងណា នោះយើងមិនដឹងទេ ទាល់តែព្រះពុទ្ធដោយការត្រាស់ ដឹងរបស់ព្រះអង្គទើបដឹងដោយទ្រង់ញាណ។

ឥឡូវខ្ញុំសូមលើកយកមកពិភាក្សា អំពីការត្រាស់ដឹងនៃព្រះពុទ្ធ តើព្រះពុទ្ធត្រាស់ដឹង ពិត មែន ឬមិនពិត ? យើងមានអំណាចសួរ ពីព្រោះយើងពុំបានឃើញ ។ ដោយយើងពុំបាន ឃើញ ដូច្នេះដើម្បីនឹងជឿបាន លុះត្រាតែមានអ្វីជាភស្តុតាងហើយសមហេតុសមផល ។ ការត្រាស់ដឹងព្រះពុទ្ធមានបីផ្នែក គឺ ១-ចតុរារិយសច្ច ២-ចំពោះសត្វលោកណាក៏ដោយ ព្រះអង្គអាចប្រមើលមើលឃើញថាសត្វលោកនោះ ធ្លាប់មានកំណើតជាអ្វី ៣- ចំពោះ សត្វដែលស្លាប់ ព្រះអង្គ ដឹងនូវភពដែលសត្វនោះបានអន្ទោលទៅកើត ។ យើងសួរថាតើ ការត្រាស់ដឹងធម៌ទាំង បីនេះ សមហេតុសមផលទេ? ឧបមា ថាព្រះអង្គមិនបានត្រាស់ ដឹងធម៌ទី ១ ។ <u>ចុះធម៌ទី១</u> នេះដែលមានរហូតដល់សព្វថ្ងៃនេះចេញមកពីណា? ហើយ ប្រសិនបើជាធម៌របស់សាសនាផ្សេង ម្តេចក៏ម្ចាស់ សាសនានោះ ឬ អ្នកកាន់សាសនានោះ មិនឃើញតវ៉ានៅពេលដែលព្រះពុទ្ធផ្សាយធម៌ទីមួយនេះដល់ បញ្ចវគ្គីយ៍ នៅពារាណសី ?

<u>ចំពោះធម៌ទី២</u> ព្រះអង្គមិនត្រឹមតែដឹងអតីតជាតិនៃសត្វលោកប៉ុណ្ណោះទេ ព្រះអង្គត្រាស់ ដឹងជាតិកំណើតព្រះអង្គទាំងអស់ ។ ដូចជាមុនជាតិចុងក្រោយ ព្រះអង្គជាព្រះវេស្សន្តរ ហើយព្រះអង្គត្រាស់ដឹងថា មុនព្រះអង្គ ក៏មានព្រះពុទ្ធរាប់រយកោដិ ដែលបានត្រាស់ដឹង

ដូចព្រះអង្គដែរ ដោយទាំងមានព្រះនាមព្រះពុទ្ធនោះផង ។ នៅជាតិខ្លះព្រះអង្គធ្លាប់កើតជាសត្វតិរច្ឆានក៏មាន ព្រះអង្គឥតមានលាក់បាំងអ្វីទាំងអស់។ ភស្តុតាងសមហេតុផលមួយទៀតគឺ ទាំងរឿងប្រវត្តិ ទាំងធម៌ដែលព្រះអង្គបានសំដែង សុទ្ធតែស្របគ្នាទាំងអស់ គឺមិនប្រឆាំងនឹងគ្នា ពីព្រោះខ្ញុំច្រើនសង្កេតឃើញចំពោះសំដីមនុស្សកុហក ច្រើនតែជាន់កែងឯង ។ ដូចកាលព្រះអង្គស្វែងរកធម៌ ធ្វើទុក្ករកិរិយា ព្រះមាតាព្រះអង្គដែលទៅកើតនៅឋានតុសិត បានចុះមកមើលព្រះអង្គ នៅឋានកណ្ដាលយើងនេះ ។ ដល់ព្រះអង្គបានត្រាស់ដឹង ព្រះអង្គបានយាងទៅប្រោសពុទ្ធមាតា នៅឋាន តាវតឹង្ស។ មកដល់ត្រង់នេះ បើព្រះអង្គមិនបានត្រាស់នូវ ធម៌ទី៣ ទេ នោះយើងអាចសួរថាតើ ព្រះអង្គដឹងថា ពុទ្ធមាតា កើតនៅឋានតុសិត ដោយរបៀបណា? ដូច្នេះមានតែព្រះអង្គត្រាស់ដឹងធម៌ទី៣នេះ ទើបព្រះអង្គទ្រង់យាងទៅដល់ ហើយទើបមានធម៌អភិធម្ម ទុកឲ្យយើងរហូតដល់សព្វថ្ងៃនេះ។

ទាំងនេះជាហេតុផល សម្រាប់លោកអ្នកយកទៅពិចារណា ក្នុងសំណួរថា ព្រះពុទ្ធបានត្រាស់ដឹងមែន ឬ មិនមែន ។ បើលោកអ្នកជឿថាមែន នោះសំណួរ ថា **តើស្លាប់ហើយកើតទៀត** មិនពិបាកឆ្លើយទេ ពីព្រោះធម៌ត្រាស់ដឹងទី២ និងទី៣ បង្ហាញថា ស្លាប់ហើយកើតទៀត រួចទៅហើយ ដូចជា ព្រះវេស្សន្តរ ឬ ព្រះពុទ្ធមាតាជាឧទាហរណ៍ស្រាប់។